# ក្បួនច្បាប់កីឡាប៉េតង់

## មាត្រាទី១ ការបង្កើតក្រុម

កីឡាប៉េតង់ត្រូវលេង:

- ៣នាក់ទល់និង៣នាក់។ ម្នាក់កាន់២គ្រាប់
- ២នាក់ទល់និង២នាក់។ ម្នាក់កាន់៣គ្រាប់
- ១ទល់និង១។ ម្នាក់កាន់៣គ្រាប់

## មាត្រាទី២ ប៊ូលទទួលស្គាល់

ការលេងកីឡាប៉េតង់ត្រូវប្រើគ្រាប់ប៊ូលដែលទទួលស្គាល់ពីសហព័ន្ធអន្តរជាតិFIPJP។
១) គ្រាប់ប៊ូលត្រូវធ្វើពីជាតិដែក
២) គ្រាប់ប៊ូលអង្កត់ផ្ចិតត្រូវមានទំហំ៧,០៥សង់ទីម៉ែត្រដល់៨,០០សង់ទីម៉ែត្រ
៣) គ្រាប់ប៊ូលត្រូវមានទម្ងន់ពី៦៥០ក្រាម ដល់ ៨០០ក្រាម ។ ឈ្មោះក្រុមហ៊ុនផលិតនិងទម្ងន់ត្រូវឆ្លាក់លើប៊ូលហើយអាចអានបាន។
ក្មេងអាយុពី១១ឆ្នាំចុះក្រោមអាចប្រើគ្រាប់ប៊ូលទម្ងន់៦០០ក្រាមនិងអង្កត់ផ្ចិត៦៥មីលីម៉ែត្របានក្នុងការប្រកួតពិសេសសំរាប់ក្មេង។
៤) ហាមមិនឲ្យបញ្ចូលសំណ, ខ្សាច់ឬអ្វីផ្សេងទៀតដែលធ្វើឲ្យគ្រាប់ប៊ូលខុសពីភាពធម្មតា។ ឈ្មោះអាចឆ្លាក់លើគ្រាប់ប៊ូលបាន។
ហាមជាដាច់ខាតដុតគ្រាប់ប៊ូលឡើងវិញដើម្បីឲ្យប៊ូលនោះមានភាពទន់ជាងប៊ូលដែលកំណត់ទុកពីក្រុមហ៊ុន។ ម៉្យាងទៀតឈ្មោះរបស់អ្នកប្រកួតអាចឆ្លាក់លើប៊ូលបាន។
ស្លាកសញ្ញា អាចឆ្លាក់បានបើសិនជារបស់នោះបានដំកល់ទុកក្នុងសៀវភៅបច្ចេកទេសរបស់ក្រុមហ៊ុន។

## មាត្រាទី២ខៈ ទណ្ឌកម្មចំពោះ ប៊ូលមិនទទួលស្គាល់

អ្នកកីឡាទាំងឡាយដែលល្មើសនិងក្បួនក្នុងកថាខណ្ឌ៤ខាងលើត្រូវបណ្ដេញចេញពីការប្រកួតព្រមទាំងដៃគូរបស់ខ្លួន។

បើសិនជាប៊ូលត្រឹមត្រូវបានប្រើការហើយប៉ុន្តែខុសមកពីការផលិតរួចហើយឥតបានទទួលស្គាល់បន្ទាប់ពីការពិនិត្យពិចៃឬមួយមិនត្រឹមត្រូវតាមកថាខណ្ឌ ១), ២), ៣) ក្នុងមាត្រាទី២ អ្នកប្រកួតត្រូវប្តូរប៊ូលនោះចេញឬប្តូរទាំងអស់។
បណ្តឹងដែលធ្វើឡើងចំពោះកថាខណ្ឌទាំង៣ខាងលើនេះត្រូវតែធ្វើឡើងមុនពេលប្រកួត។ អ្នកដែលប្តឹងត្រូវតែឆែកមើលប៊ូលរបស់គាត់និងប៊ូលរបស់គូប្រជែងបានត្រឹមត្រូវមុនពេលប្រកួត។
ផ្ទុយទៅវិញបណ្តឹងពាក់ព័ន្ធនិងកថាខណ្ឌ ទី៤) អាចធ្វើបានគ្រប់ពេលក្នុងពេលកំពុងប្រកួត ប៉ុន្តែបើសិនជាបណ្តឹងនេះចាប់ធ្វើពីសេវាទី៣ទៅ, ហើយបើឃើញថាបណ្តឹងនោះវាខុសអ្នកដែលប្តឹងនោះត្រូវពិន័យដោយបន្ថែម៣ពិន្ទុឲ្យទៅក្រុមអ្នកត្រូវ។
អាជ្ញាកណ្តាលឬគណៈវិនិច្ឆ័យអាចត្រួតពិនិត្យប៊ូលអ្នកប្រកួតបានគ្រប់ពេលវេលាក្នុងពេលកំពុងប្រកួត។

## មាត្រាទី៣ ប៊ីទទួលស្គាល់

គ្រាប់ប៊ី ឫ កូសូនេ(cochonnet)ទំហំ៣០មីលីម៉ែត្រអង្កត់ផ្ចិត(អធ្យាស្រ័យត្រឹម១មីលីម៉ែត្របូកឬដក)។ទម្ងន់ពី១០ដល់១៨ក្រាម ត្រូវធ្វើអំពីឈើឬពីប្លាស្ទិច ហើយត្រូវតែមានម៉ាកសញ្ញាត្រឹមត្រូវពីក្រុមហ៊ុនផលិតដែលទទួលស្គាល់ ពីសហព័ន្ធអន្តរជាតិ។ គ្រាប់ប៊ី អាចលាបព័រណ៍បាន ក៏ប៉ុន្តែមិនអាចលើកឡើងបានដោយប្រើដែកឆក់។

## មាត្រាទី៤ អាជ្ញាប័ណ្ណ

មុនពេលចាប់ផ្តើមប្រកួតអ្នកកីឡាត្រូវបង្ហាញអាជ្ញាប័ណ្ណ។ អាជ្ញាកណ្តាលអាចសុំមើលអាជ្ញាប័ណ្ណអ្នកប្រកួតពេលណាក៏បាន ។ អ្នកប្រកួតក៏មានសិទ្ធិសុំមើលអាជ្ញាប័ណ្ណគូប្រជែងដែរ។ អាជ្ញាប័ណ្ណចេញអោយពីសហព័ន្ធក្នុងប្រទេសហើយត្រូវតែមានបោះត្រាសហព័ន្ធលើរូបថត និងឈ្មោះអ្នកចេញឲ្យព្រមទាំងហត្ថលេខានៃសាមីខ្លួន។

# ការប្រកួត

## មាត្រាទី៥ កន្លែងប្រកួតនិងទីលានប្រកួតត្រឹមត្រូវ

កីឡាប៉េតង់អាចលេងបានគ្រប់ទីលាន។ បើទីលាននោះមានខ្នាតត្រឹមត្រូវដែលព័ទ្ធដោយខ្សែដែលមានទំហំមិនរំខានការប្រកួត។ ទំហំរបស់ទីលានគឺ៤ម៉ែត្រទទឹងនិង១៥ម៉ែត្របណ្តោយ

សំរាប់ការប្រកួតរើសជើងឯកក្នុងប្រទេស នឹងការប្រកួតជាលក្ខណៈអន្តរជាតិ។ ទីលានអាចមានទំហំ១២ម៉ែត្របណ្តោយហើយ៣ម៉ែត្រទទឹងបាន បើការប្រកួតនោះមានលក្ខណៈផ្សេងទៀត។
បើសិនជាទីលាននោះមានរបងព័ទ្ធជុំវិញ, របងនោះត្រូវមានចម្ងាយយ៉ាងតិច១ម៉ែត្រពីខ្សែទី។

ខ្សែបន្ទាត់ដែលពុះចែកទីលានមិនមែនជាខ្សែទីនោះទេ។ខ្សែទីជាខ្សែខាងក្រៅនិងខ្សែដែលកំណត់ដោយគណកម្មការ។
ពិន្ទុនៃការប្រកួតត្រឹម១៣ប៉ុន្តែអាចបញ្ចុះដល់១១បានក្នុងការប្រកួតក្នុងវគ្គជំរុះ។
ការប្រកួតកំណត់ពេលវេលាត្រូវធ្វើជាចាំបាច់ក្នុងទីលានកំណត់ខ្នាត ហើយខ្សែបន្ទាត់ទាំងអស់គឺជាខ្សែទីដែលមិនឆ្លងដែនបាន។

## <u>មាត្រាទី៦ ការចាប់ផ្តើមប្រកួតនិងការប្រើរង្វង់មូល</u>

គូប្រកួតទាំង២ក្រុមត្រូវចាប់ឆ្នោតជ្រើសរើសទីលានសម្រាប់ប្រកួត។ បើសិនជាទីលានជ្រើសរើសនោះមិនអាចលេងបានដោយសារមានការជំទាស់ពីអ្នករៀបចំការប្រកួតឬអាជ្ញាកណ្តាលអ្នកឈ្នះឆ្នោតត្រូវបានស្វាគមណ៍ឲ្យរើសទីលានថ្មីដែលមានភាពអក្សាក្រិតរួចប្រាប់អាជ្ញាកណ្តាលឲ្យដឹងកន្លែងថ្មីមុននឹងប្រកួត។
ក្រុមឈ្នះឆ្នោតត្រូវគូររង្វង់មូលដែលមានអង្កត់ផ្ចិតទំហំពី៣៥ដល់៥០សង់ទីមែត្រឲ្យមានកន្លែងដាក់ជើងទាំង២បាន ឬ ប្រើរង្វង់មូលដែលធ្វើរួចស្រាប់មានទំហំអង្កត់ផ្ចិត៥០សង់ទីម៉ែត្រ (អធ្យាស្រ័យបាន២សង់ទីម៉ែត្របូកឬដក)។
រង្វង់មូលធ្វើរួចស្រាប់អាចទទួលស្គាល់បានលុះត្រាមានការទទួលស្គាល់ពីសហពន្ធ័អន្តរជាតិ (FIPJP)។ បើសិនជាអ្នករៀបចំការប្រកួតបានបញ្ជាឲ្យប្រើរង្វង់មូលរបស់គាត់ដែលត្រឹមត្រូវតាមក្បួន,អ្នកប្រកួតត្រូវធ្វើតាម។ពេលដាក់រង្វង់លើដីត្រូវគូសបញ្ជាក់ទីកន្លែងរបស់រង្វង់មុននិងបោះគ្រាប់ប៊ី។
គេមានសិទ្ធិបោះប៊ីពីរង្វង់មូលបានតែ១ដងទេ បើសិនជាការបោះនោះមិនបានត្រឹមត្រូវតាមក្បួន, គូប្រជែងត្រូវតែយកកូនប៊ីនោះដាក់កន្លែងណាក៏បានដែរឲ្យតែត្រូវតាមក្បួនច្បាប់។ រង្វង់មូលត្រូវតែគូរឬដាក់ឆ្ងាយពីឧបសគ្គ១ម៉ែត្រនិងឃ្លាតឆ្ងាយ២ម៉ែត្រពីរង្វង់មូលមួយទៀតដែលគេកំពុងលេង ។ ក្រុមប្រកួតដែលបោះកូនប៊ីត្រូវតែលប់ចោលនូវរង្វង់ជិតខាងមុននិងបោះប៊ី។ ក្នុងរង្វង់មូលអាចបោសសំអាតបាន។ ពេលចប់សេវានិមួយៗរង្វង់មូលត្រូវតែសំអាតឲ្យដូចដើមវិញ។ កន្លែងក្នុងរង្វង់មូលមិនអាចទុកជាកន្លែងហាមឃាត់ទេ។ ជើងទាំង២ត្រូវតែស្ថិតក្នុងរង្វង់មិនឲ្យប៉ះឬជាន់លើរង្វង់នោះហើយអាចចេញពីរង្វង់បានក្នុងពេលណាដែលគ្រាប់ប៊ូ

លដែលបោះនោះធ្លាក់ដល់ដី មិនតែប៉ុណ្ណោះរាងកាយផ្សេងទៀតក៏មិនត្រូវប៉ះដីដែរ។ប៉ុន្តែមានការអធ្យាស្រ័យដល់ កីឡាករពិការដែលមានតែជើងមួយ។ កីឡាករពិការដែលអង្គុយលើរទេះដែលមានកង់២ត្រូវឲ្យកង់ម្ខាងនៃរទេះរបស់គាត់ស្ថិតក្នុងរង្វង់មូល។
អ្នកដែលបោះប៊ីមិនចាំបាច់បោះប៊ូលមុនគេទេឲ្យតែអ្នកក្នុងក្រុមរបស់គាត់មួយណាក៏អាចបោះបានដែរ។ បើសិនជាកីឡាករម្នាក់ដករង្វង់មូលចេញហើយដៃគូរបស់គាត់នៅសល់ប៊ូល ប៊ូលសល់ទាំងនោះមិនអាចឲ្យបន្តលេងទេ។

## មាត្រាទី៧ ចម្ងាយនៃការបោះកូនប៊ី . ការបោះបានតែមួយដងគត់

ដើម្បីឲ្យការបោះប៊ីទទួលស្គាល់ត្រូវតែះ
១)ចម្ងាយពីកូនប៊ីទៅរង្វង់មូលផ្ទៃតូចមានចម្ងាយដូចតទៅ:

៦ទៅ១០ម៉ែត្រសម្រាប់វ័យ១៥ឆ្នាំឡើងទៅ។ក្នុងការប្រកួតសំរាប់វ័យក្មេងបំផុត, ចម្ងាយនេះអាចបន្ថយបាន។
២) រង្វង់មូលត្រូវតែមានចម្ងាយយ៉ាងតិច១ម៉ែត្រពីឧបសគ្គនិងនិង២ម៉ែត្រពីរង្វង់មូលមួយទៀត។
៣) កូនប៊ីត្រូវតែមានចម្ងាយយ៉ាងតិច១ម៉ែត្រពីឧបសគ្គឬខ្សែទីឫខ្សែព្រុះទីលានដែលមិនអនុញ្ញាតឲ្យលេង។ ចម្ងាយនេះអាចបន្ថយដល់៥០សង់ទីម៉ែត្របានបើសិនជាការប្រកួតនោះមានកម្រិតពេលវេលាប៉ុន្តែមិនអាចបន្ថយបានពីខ្សែទីខាងមុខឫខាងក្រោយរបស់ទីលានកំពុងប្រកួត។
៤)ប៊ីដែលបោះរួចត្រូវតែអាចឲ្យអ្នកលេងមើលឃើញពីក្នុងរង្វង់មូលដោយឈរត្រង់ខ្លួន។បើសិនជាមានការតវ៉ាអាជ្ញាកណ្តាលជាអ្នកសម្រេច។ ពេលចប់សេវាប្រកួតអ្នកដែលបោះកូនប៊ីសម្រាប់សេវាថ្មីត្រូវគូររង្វង់មូលថ្មីឬដាក់រង្វង់ដែលធ្វើស្រាប់ជុំវិញកូនប៊ីរួចលេងបន្តបើសិនជាគ្មានករណីខាងក្រោមនេះកើតឡើងះ

- រង្វង់មូលមានចម្ងាយខ្លីជាង១ម៉ែត្រពីឧបសគ្គ
- កូនប៊ីមិនស្ថិតនៅចម្ងាយសម្រាប់ការបោះប៊ីដែលចែងក្នុងក្បួន

ក្នុងករណីទី១អ្នកកីឡាគូររង្វង់ឬដាក់រង្វង់តាមខ្នាតត្រឹមត្រូវ។
ក្នុងករណីទី២អ្នកបោះប៊ីអាចថយក្រោយបានតាមបន្ទាត់ត្រង់ពីកូនប៊ីទៅរង្វង់ចាស់មិនឲ្យលើសពីចម្ងាយអតិបរមា។
បើសិនជាការបោះកូនប៊ីនោះមិនត្រឹមត្រូវតាមក្បួនដូចចែងខាងលើ គេត្រូវតែដូរឲ្យគូប្រជែង

ដាក់ប៊ីកន្លែងណាក៏បានឲ្យតែត្រឹមត្រូវតាមក្បួនរបស់ប៊ី។ អាចថយរង្វង់មូលមកក្រោយបានបើសិនជាចម្ងាយពីរង្វង់មូលមិនអនុញ្ញាតឲ្យដាក់ប៊ីបានតាមក្បួននៃប៊ីដូចខាងលើ។ ទោះជាយ៉ាងណាក៏ដោយក្រុមដែលបរាជ័យក្នុងការបោះប៊ីត្រូវតែផ្តើមបោះប៊ូលមុន។ ក្រុមដែលបោះប៊ីមានសិទ្ធិត្រឹមតែ១នាទីសម្រាប់បោះឯក្រុមដែលដាក់ប៊ីត្រូវតែដាក់ប៊ីជាបន្ទាន់បន្ទាប់ពីគូប្រជែងបោះរួច។

## មាត្រាទី៨ការទទួលស្គាល់នៃការបោះកូនប៊ី

បើសិនជាកូនប៊ីដែលបោះទៅរួចប៉ះអាជ្ញាកណ្ដាល, គូប្រជែង, អ្នកទស្សនា, សត្វ, ឬរបស់អ្វីដែលកំពុងធ្វើចលនា, គ្រាប់ប៊ីនោះត្រូវតែបោះឡើងវិញ ។ បើកូនប៊ីប៉ះដៃគូខ្លួនឯង,គូប្រជែងអាចយកគ្រាប់ប៊ីនោះដាក់កន្លែងណាក៏បានឲ្យតែត្រូវតាមក្បួនច្បាប់នៃការបោះប៊ី។ កូនប៊ីបានបោះហើយៗប៊ូលទី១បានបោះរួច, គូប្រជែងនៅតែមានសិទ្ធិតវ៉ានិងកំហុសរបស់កូនប៊ីប៉ុន្តែបើសិនជាកូនប៊ីនោះចាប់ដាក់ដោយគូប្រជែងការតវ៉ាទុកជាមោឃះ។

បន្ទាប់ពីបោះឬដាក់កូនប៊ីរួចហើយបើសិនឃើញថាវាមិនត្រឹមត្រូវ,កូនប៊ីត្រូវតែបោះឬដាក់ឡើងវិញហើយប៊ូលដែលបោះរួចក៏ត្រូវបោះឡើងវិញ។ បើសិនជាគូប្រជែងបានបោះមួយដៃរ,ពេលនោះការប្រកួតត្រូវបន្តជាធម្មតា។

មុននឹងប្រគល់កូនប៊ីឲ្យក្រុមម្ខាងទៀតដាក់ក្រុមទាំង២ត្រូវតែយល់ព្រមគ្នាឬអាជ្ញាកណ្ដាលទទួលស្គាល់។បើសិនជាក្រុមណាមួយជំទាសនឹងការសម្រេចហ្នឹងក្រុមនោះនឹងបាត់សិទ្ធិក្នុងការបោះប៊ី។

ប៊ីបោះហើយប៊ូលទី១និងប៊ូលទី២បានបោះហើយការតវាទុកជាមោឃៈ។

## មាត្រាទី៩ គ្រាប់ប៊ីមិនត្រឹមត្រូវ

ប្រការទាំង៧ខាងក្រោមនេះចាត់ទុកគ្រាប់ប៊ីជាអសារបង់៖

១)បើសិនជាបន្ទាប់ពីការបោះគ្រាប់ប៊ីហើយឃើញថាគ្រាប់ប៊ីនោះមិនមានលក្ខណះដូចចែងក្នុងមាត្រាទី៧ ។

២) ពេលកំពុងប្រកួតស្រាប់តែគ្រាប់ប៊ីចេញពីខ្សែទីរួចជះចូលមកទីលានវិញឬគ្រាប់ប៊ីអណ្ដែតលើទឹកមិនអាចលេងបាន។

៣) គ្រាប់ប៊ីនៅក្នុងទីលានតែមើលមិនឃើញពីរង្វង់មូល៕ ប៊ីដែលមើលមិនឃើញដោយសារតែបាំងនិងប៊ូលយកជាបានការ។ អាជ្ញាកណ្ដាលមានសិទ្ធិលើកគ្រាប់ប៊ូល

ចេញដើម្បីសន្និដ្ឋានថាតើបឺនោះមើលឃើញឬមិនឃើញ។
៤) បើក្នុងពេលកំពុងប្រកួតស្រាប់តែកូនបឺប្តូរចម្ងាយលើសពី២០ម៉ែត្រឬតិចជាង៣ម៉ែត្រពីរង្វង់មូល។
៥) បើក្នុងពេលកំពុងប្រកួតស្រាប់តែគ្រាប់បឺរកមិនឃើញហើយការស្វែងរកគ្រាប់បឺមកវិញបានត្រឹមតែ៥នាទីប៉ុណ្ណោះ។
៦) បើសិនជាទីលានហាមឃាត់ស្ថិតនៅចន្លោះគ្រាប់បឺនិងរង្វង់មូល។
៧) បឺខ្ទាតចេញពីដំបន់ដែលគេកំណត់ឲ្យលេង។

## មាត្រាទី១០  ការកែប្រែទីលានប្រកួតឬយកចេញឧបសគ្គ

ហាមយកចេញ,ជាន់ឈ្លីឬបោសចេញនូវរបស់អ្វីដែលមានក្នុងទីលានកំពុងប្រកួតដែលអ្នកប្រកួតយល់ថាជាការរារាំង។ ប៉ុន្តែអ្នកដែលបម្រុងបោះកូនបឺអាច
គោះដីបាន៣ដងមុននឹងបោះបឺដើម្បីចង់ដឹងថាតើកន្លែងដែលគេចង់ឲ្យប៊ូលធ្លាក់នោះទន់ឬរឹង។ លើសពីហ្នឹងទៅទៀតអ្នកដែលបម្រុងនិងបោះប៊ូលឬដៃគូរបស់គាត់អាចបិទរន្ធដែលប៊ូលធ្លាក់ពីមុនបាន១រន្ធ។ បើសិនជាអ្នកកីឡាមិនធ្វើតាមបំរាមមខាងលើនាក់នេះនិងត្រូវពិន័យដូចត៍ទៅ៖

១) ត្រូវព្រមាន

២) ទុកជាអសារបង់ប៊ូលដែលបោះរួចឬប៊ូលដែលត្រូវបោះ
៣) បញ្ឈប់ឲ្យប្រកួតទាំងក្រុម
៤) បញ្ឈប់ឲ្យប្រកួតទាំង២ក្រុមបើសិនជាមានការឃុបឃិតគ្នា

## មាត្រាទី១១ ការដូរប៊ូលឬបឺ

អ្នកកីឡាមិនអាចដូរបឺឬប៊ូលក្នុងពេលកំពុងប្រកួត,លើកលែងតែ៖
១) ប៊ូលឬបឺរកមិនឃើញក្នុងពេលកំពុងប្រកួត។ ការស្វែងរកអនុញ្ញាតឲ្យតែ៥នាទីប៉ុណ្ណោះ។
២) បើសិនជាប៊ូលឬបឺបែកជា២ឬជាច្រើនដុំ, ដុំធំជាងគេត្រូវទុកជាបានការ។ ការប្រកួតត្រូវតែបន្តបើសិនជានៅសល់ប៊ូលហើយដុំប៊ូលឬដុំបឺដែលទុកជាបានការត្រូវដូរចេញនឹងប៊ូលឬបឺដែលមានទំហំដូចគ្នាឬប្រហែលគ្នា,បន្ទាប់ពីការវាស់វែងរួច។ ពេលសេវាប្រកួតចប់កាលណាអ្នកដែលកាន់ប៊ូលបែកអាចដូរចេញទាំង២ឬទាំង៣ក៏បានដែរ។

# គ្រាប់បី

## មាត្រាទី១២ ប៊ីមើលមិនឃើញឬប្តូរទីកន្លែង

បើសិនជាពេលកំពុងប្រកួតស្រាប់តែស្លឹកឈើឬក្រដាស់បានគ្របកូនប៊ី, របស់ទាំងនោះត្រូវតែដកចេញ។

បើសិនជាកូនប៊ីត្រូវប្តូរទីកន្លែងដោយមូលហេតុមកពីខ្យល់មកពីដីចំណោតមកពីអាជ្ញាកណ្តាល, អ្នកប្រកួត, អ្នកទស្សនា, ប៊ូលឬប៊ីដែលមកពីទីលានប្រកួតជិតខាង, សត្វឬរបស់អ្វីមួយដែលមានចលនា, ប៊ីនោះត្រូវតែដាក់ទៅកន្លែងដើមវិញបើសិនជាប៊ីនោះមានគូសចំណាំកន្លែង។ ដើម្បីជៀសវាងការតវាអ្នកប្រកួតត្រូវតែគូសចំណាំកន្លែងប៊ីឬប៊ូល។ បើមិនដូច្នោះទេការតវាទុកជាអសារបង់។ បើសិនជាប៊ីប្តូរទីកន្លែងដោយប៊ូលកំពុងប្រកួត,ការគូសឬមិនគូសចំណាំក៏ទុកជាបានការ។

## មាត្រាទី១៣ ប៊ីចូលទៅទីលានប្រកួតមួយទៀត

ប៊ីចេញទៅទីលានប្រកួតមួយទៀតប៊ីនោះទុកជាបានការបើសិនជាករណីនេះគ្មានការប៉ះពាល់ដល់មាត្រាទី៩ដែលចែងខាងលើ។ ការប្រកួតបន្តរត្រូវតែចាំទាល់តែសេវាប្រកួតរបស់ម្ចាស់ទីលានចប់សិន។ អ្នកប្រកួតត្រូវតែមានការអត់ធ្មត់រង់ចាំ។  ពេលចប់សេវាប្រកួតហើយ,អ្នកខ្ចីទីលានគេត្រូវមកកន្លែងខ្លួនវិញហើយរង្វង់មូលថ្មីត្រូវតែធ្វើឡើងពីកន្លែងដែលមុនប៊ីផ្លាស់ប្តូរទីតាំង។ករណីនេះចាត់ទុកជាត្រឹមត្រូវបើគ្មានជំទាស់ពីមាត្រាទី៧។

## មាត្រាទី១៤ កូនប៊ីចេញពីខ្សែទី

៣ករណីត្រូវយកមកប្រើ៖

១)បើក្រុមប្រកួតនិមួយៗនៅសល់គ្រាប់ប៊ូល វគ្គប្រកួតទុកជាអសារបង់។

២)បើក្រុមមួយនៅសល់ប៊ូលហើយក្រុមមួយទៀតអស់ប៊ូល ក្រុមដែលនៅសល់ប៊ូលត្រូវបានពិន្ទុតាមចំនួនប៊ូលដែលនៅសល់ទាំងអស់។

៣) បើក្រុមប្រកួតនិមួយៗអស់គ្រាប់ប៊ូល វគ្គប្រកួតទុកជាអសារបង់។

## មាត្រាទី១៥ កូនប៊ីត្រូវបញ្ឈប់ដោយអ្វីមួយ

បើសិនជាកូនប៊ីដែលត្រូវគេវាយហើយប៉ះអ្នកទស្សនាឬអាជ្ញាកណ្តាលគ្រាប់ប៊ីនោះត្រូវរក្សាទីកន្លែងថ្មី។

បើសិនជាគ្រាប់ប៊ីដែលត្រូវគេវាយហើយប៉ះអ្នកប្រកួតម្នាក់ក្នុងទីលាន,ក្រុមប្រជែងមានសិទ្ធិ

ជ្រើសរើសករណីមួយក្នុងករណីទាំង៣ខាងក្រោម៖
ក)ទុកគ្រាប់ប៊ីនៅកន្លែងថ្មី
ខ) ដាក់ប៊ីទៅកន្លែងចាស់វិញ
គ) ដាក់ប៊ីនៅលើកន្លែងណាមួយតាមខ្សែបន្ទាត់ទាញពីកន្លែងថ្មីទៅកន្លែងចាស់ដែលមានចម្ងាយយ៉ាងឆ្ងាយ២០ម៉ែត្រពីរង្វង់មូល។ ចំពោះយុវវ័យដែលក្មេងបំផុតចម្ងាយនោះអាចបន្ថយត្រឹម១៥ម៉ែត្រ។ ក្នុងករណី ខ) និង គ) អាចធ្វើបានតែពេលណាដែលកូនប៊ីបានគូសសំគាល់កន្លែងរបស់វា បើមិនដូច្នេះកូនប៊ីត្រូវតែរក្សាកន្លែងថ្មី។
បើសិនជាកូនប៊ីដែលត្រូវគេវាយនោះឆ្លងកាត់ខ្សែទីហើយត្រឡប់មកវិញ កូនប៊ីនោះទុកជាអសារបង់។ គេយកមាត្រាទី១4មកអនុវត្ត។

# គ្រាប់ប៊ូល

## មាត្រាទី១៦ ការបោះប៊ូលដំបូងនិងប៊ូលបន្ទាប់

ប៊ូលទីមួយបានបោះរួចហើយពីក្រុមអ្នកឈ្នះឆ្នោតឬក្រុមដែលឈ្នះសេវាមុនបន្ទាប់មកក្រុមប្រដែងបោះម្តង។ អ្នកប្រកួតមិនអាចប្រើអ្វីមួយឬគូសចំណាំកន្លែងដែលគាត់ចង់ឲ្យប៊ូលដែលនឹងបោះរបស់គាត់ធ្លាក់ចំទីនោះ។
ក្នុងការបោះប៊ូលចុងក្រោយរបស់អ្នកកីឡាករម្នាក់, អ្នកនោះមិនអនុញ្ញាតឲ្យកាន់គ្រាប់ប៊ូលនៅដៃម្ខាងទៀតទេ។
ប៊ូលត្រូវបោះម្តងតែមួយគ្រាប់, ប៊ូលដែលបោះហើយមិនអាចបោះឡើងវិញបានទេ។ អាចបោះឡើងវិញបានលុះត្រាតែប៊ូលនោះត្រូវបញ្ឈប់ដំណើរនៅចន្លោះរង្វង់មូលនិងគ្រាប់ប៊ីដោយអ្វីៗដូចជាប៊ូលដែលឆ្លងមកពីក្រុមប្រកួតមួយទៀត,ដោយសត្វឬដោយរបស់អ្វីមួយដែលមានចលនា,ឧទាហរណ៍ដូចជាគ្រាប់បាល់ជាដើម។ករណីនេះបានរៀបរាប់ក្នុងមាត្រាទី៨,ចំណុចទី២។ ហាមធ្វើឲ្យគ្រាប់ប៊ូលឬគ្រាប់ប៊ីសើម។
មុននិងបោះគ្រាប់ប៊ូលគេត្រូវតែសំអាតគ្រាប់ប៊ូលដោយកុំឲ្យមានភក់ឬរបស់អ្វីផ្សេងទៀតជាប់លើនោះ។ បើមិនធ្វើដូច្នេះទេគេអាចពិន័យតាមមាត្រា៣៥។
បើសិនជាប៊ូលដែលបោះទីមួយធ្លាក់ចូលទីកន្លែងដែលហាមឃាត់ ត្រូវឲ្យគូប្រដែងបោះម្តង។ បើសិនជាប៊ូលរបស់គូប្រដែងក៏ធ្លាក់ចូលទីហាមឃាត់ដែរត្រូវឲ្យក្រុមម្ខាងទៀតបោះម្តងវិញ៕ ករណីបោះម្នាក់ម្តងនេះ ត្រូវតែបន្តរដល់រកអ្នកឈ្នះឃើញ។

បើសិនជាដល់ទីបញ្ចប់គ្មានសល់ប៊ូលមួយសោះក្នុងទីលានប្រកួតបន្ទាប់ពីវាយឬចូលប៊ូល
របស់ក្រុមណាមួយ,គេត្រូវយកមាត្រា២៩មកវិនិច្ឆ័យ។

## មាត្រាទី១៧ អាកប្បកិរិយារបស់អ្នកកីឡានិងអ្នកមកទស្សនាក្នុងពេលប្រកួត

ក្នុងការបោះគ្រាប់ប៊ូលអ្នកកីឡាមានសិទ្ធិប្រើពេលវេលារបស់គាត់ដែលក្បួនចែងឲ្យហើយក្នុង
រយះពេលនោះអ្នកកីឡាករនិងអ្នកទស្សនាត្រូវតែរក្សាសេចក្តីស្ងប់ស្ងៀម។ គូប្រជែងរបស់
គាត់មិនត្រូវដើរឬធ្វើចលនាណាមួយដែលអាចរំខានអ្នកប្រុងនឹងបោះ។ មានតែដៃគូប្រកួត
របស់គាត់ទេដែលអាចមានសិទ្ធិនៅចន្លោះរង្វង់មូលនិងកូនប៊ី។
គូប្រជែងត្រូវតែឈរ២ម៉ែត្រពីកូនប៊ីទៅខាងក្រោយចំហៀងឬ២ម៉ែត្រចំហៀងក្រោយរង្វង់មូ
ល។ អ្នកប្រកួតទាំងអស់ត្រូវតែគោរពវិន័យនេះបើមិនធ្វើតាមទេអាជ្ញាកណ្តាលនឹងព្រមាន,បើ
នៅតែល្មើសអ្នកនោះអាចនឹងត្រូវបញ្ឈប់ឲ្យប្រកួត។

## មាត្រាទី១៨ ការបោះប៊ូលនិងប៊ូលចេញក្រៅទីលាន

ហាមបោះប៊ូលសាកមើលឬបោះកំដៅសាច់ដុំក្នុងពេលកំពុងប្រកួត។ អ្នកដែលប្រព្រឹត្តអំពើនេះ
នឹងអាចដាក់ទណ្ឌកម្មដូចក្នុងមាត្រា៣៥ក្នុងចំណងជើងវិន័យ។

ក្នុងពេលកំពុងប្រកួតគ្រាប់ប៊ូលដែលចេញទៅទីលានមិនហាមឃាត់ទុកជាបានការ បើសិនជា
គ្មានការជំទាស់ពីមាត្រាទី១៩។

## មាត្រាទី១៩ ប៊ូលទុកជាអសារបង់

ប៊ូលដែលចាកចេញពិទីលានមួយរួចចូលទីលានមួយទៀតចាត់ទុកជាអសារបង់កាលណាខ្សែ
ខ័ណ្ឌជាខ្សែទី។ប៊ូលដែលជាប់និងខ្សែទី អាចទុកជាអសារបង់បានលុះត្រាតែទំហំនៃប៊ូលទាំង
ស្រុងចាកចេញពីខ្សែនោះ៕
ប៊ូលដែលចេញពីខ្សែទីរួចត្រឡប់មកវិញត្រូវទុកជាអសារបង់៕ របស់ អ្វីក្នុងទីលានប្រកួតដែល
ត្រូវដូរកន្លែងដោយសារប៊ូលអសារបង់នោះត្រូវដាក់ទៅកន្លែងដើមវិញ។
ប៊ូលអសារបង់ត្រូវដកចេញពីទីលានប្រកួតភ្លាមមុនគូប្រជែងបោះប៊ូលគាត់។ បើមិនដូច្នេះទេប៊ូ
លអសារបង់ហ្នឹងទុកជាប៊ូលត្រឹមត្រូវ៕

## មាត្រាទី២០ ប៊ូលបញ្ឈប់

. ប៊ូលដែលបោះហើយត្រូវបញ្ឈប់ឬដូរទឹសដៅដោយអចេតនាពីសំណាក់អាជ្ញាកណ្តាលឬពីអ្នកទស្សនាប៊ូលនោះត្រូវដាក់នៅទីកន្លែងដែលឈប់នោះ។

ប៊ូលដែលបោះហើយត្រូវបញ្ឈប់ឬដូរទឹសដៅដោយអចេតនាពីសំណាក់ដៃគូគ្នាឯងត្រូវទុកជាអសារបង់។

ប៊ូលចូលដែលត្រូវគូប្រដែងបញ្ឈប់ឬដូរទឹសដោយអចេតនាពីសំណាក់គូប្រដែងប៊ូលនោះអាចបោះឡើងវិញឬដាក់នៅកន្លែងដែលវាឈប់។

បើសិនជាប៊ូលត្រូវគេវាយរួចត្រូវបញ្ឈប់ឬដូរទឹសដៅដោយអចេតនាពីសំណាក់អ្នកប្រកួត, គូប្រដែងនៃអ្នកបញ្ឈប់អាចជ្រើសរើសបាន២ខ:

១)អាចយកកន្លែងដែលវាឈប់

២)អាចយកកន្លែងណាមួយនៅលើបន្ទាត់ដែលគេទាញពីកន្លែងចាស់ដល់កន្លែងថ្មី ក្នុងទីលានប្រកួតដែលអនុញ្ញាត។ ករណីនេះអាចទទួលស្គាល់បានលុះត្រាតែប៊ូលត្រូវគេវាយនោះបានគូសចំណាំកន្លែង។

បើសិនជាគ្រាប់ប៊ូលត្រូវបញ្ឈប់ឬដូរទឹសដៅដោយចេតនាពីសំណាក់អ្នកប្រកួតណាមួយ, អ្នកនោះនិងក្រុមរបស់គាត់ត្រូវបញ្ឈប់ឲ្យប្រកួតក្នុងការប្រកួតនេះ។

## មាត្រាទី២១ កំណត់ពេលវេលាដែលអនុញ្ញាតឲ្យបោះប៊ូល

បន្ទាប់ពីកូនប៊ីបោះហើយគូប្រកួតទាំងអស់មានសិទ្ធិយ៉ាងច្រើនមួយនាទីសំរាប់បោះប៊ូលរបស់ខ្លួន។ ពេលវេលានេះគឺរាប់ពីពេលណាដែលប៊ូលឬប៊ីបានឈប់ធ្វើចលនាឬបន្ទាប់ពីការវាស់វែងរួច។

ការបោះប៊ីក្នុងមួយសេវានៃការប្រកួតក៏ត្រូវតែគោរពតាមច្បាប់នេះដែរ។ អ្នកកីឡាដែលមិនគោរពប្រការនេះត្រូវពិន័យតាមមាត្រា៣៥។

## មាត្រាទី២២ ប៊ូលប្តូរទីកន្លែង

បើសិនជាប៊ូលឈប់ហើយស្រាប់តែបន្តដំណើរដោយសារតែត្រូវខ្យល់បក់ឬដោយសារដីចំណោតប៊ូលនោះត្រូវតែដាក់ទៅកន្លែងដើមវិញក៏ដូចជាប៊ូលដែលបានបញ្ឈប់ដោយអចេតនាពីអាជ្ញាកណ្តាល, អ្នកប្រកួត អ្នកទស្សនា, សត្វ ឬដោយសាររបស់អ្វីដែលមានចលនា។

ដើម្បីជៀសវាងនូវការតវា, អ្នកប្រកួតទាំងអស់ត្រូវតែគូសចំណាំកន្លែងដែលប៊ូលឈប់នៅស្ងៀម។ គ្មានការតវាទេក្នុងករណីដែលប៊ូលមិនបានគូសចំណាំ។ បើសិនជាប៊ូលមិនគូសចំណាំត្រូវបានប្តូរទីកន្លែងដោយសារប៊ូលមួយទៀតដែលកំពុងលេង,កន្លែងថ្មីនោះទុកជាបានការ។

## មាត្រាទី២៣ បោះប៊ូលអ្នកដំទៃ

អ្នកប្រកួតដែលបោះប៊ូលរបស់អ្នកដំទៃត្រូវមានការព្រមានហើយត្រូវប្តូរប៊ូលចេញជាបន្ទាន់បន្ទាប់ពីវាស់វែងរួច។
បន្ទាប់ពីការព្រមានបើសិនជាអ្នកដំដែលនោះល្មើសម្តងទៀត,ប៊ូលនោះត្រូវទុកជាអសារបង់ ហើយអ្វីៗដែលត្រូវប៊ូលនោះប៉ះហើយដូរទីកន្លែង,ត្រូវដាក់មកកន្លែងដើមវិញ។

## មាត្រាទី២៤ ប៊ូលបោះផ្ទុយពីក្បូន

ប៊ូលទាំងឡាយណាដែលបោះខុសពីក្បូនទុកជាអសារបង់។ អ្វីៗដែលត្រូវដូរទីកន្លែងដោយសារប៊ូលនោះត្រូវតែដាក់មកទីកន្លែងដើមវិញបើសិនជាមានការគូសចំណាំ។
មានការលើកលែងឲ្យបានក្នុងករណីដែលក្បូនច្បាប់នេះបានត្រូវប្រើទណ្ឌកម្មយ៉ាងម៉ត់ចត់ក្នុងមាត្រា៣៥។
គូប្រជែងមានសិទ្ធិប្រើនូវក្បូនច្បាប់<u>មានព្រាប</u>(règle avantage)ហើយប្រកាសថាប៊ូលខុសនេះទុកជាបានការ ហើយអ្វីៗដែលប្តូរទីកន្លែងទុកនៅកន្លែងថ្មី។

# ពិន្ទុនិងការវាស់វែង

## មាត្រាទី២៥ ដកប៊ូលចេញបណ្តោះអាសន្ន

គេអាចដកប៊ូលនិងឧបសគ្គចេញបានក្នុងពេលណាដែលប៊ូលនិងឧបសគ្គទាំងនោះធ្វើឲ្យមានការពិបាកក្នុងការវាស់វែងបន្ទាប់ពីគូសចំណាំរួច។ បន្ទាប់ពីការវាស់វែងរួចហើយប៊ូលនិងឧបសគ្គទាំងនោះត្រូវដាក់មកទីកន្លែងដើមវិញ។ បើសិនជាឧបសគ្គទាំងនោះមិនអាចដកចេញបានការវាស់វែងត្រូវតែប្រើត្រីវិស័យ។

## មាត្រាទី២៦ ការវាស់វែង

អ្នកដែលបោះប៊ូលក្រោយគេនិងមិត្តប្រកួតរបស់គាត់ត្រូវទទួលការខុសត្រូវក្នុងការវាស់វែង។
គូប្រជែងមានសិទ្ធិនិងសុំវាស់បន្ទាប់ពីការវាស់វែងរួច។ បើសិនជាមានការមិនយល់ព្រមគេអាចហៅអាជ្ញាកណ្តាលមកវាស់ហើយសម្រេច។ការសម្រេចរបស់អាជ្ញាកណ្តាលមិនអាចតវ៉ាបានទេ។ ការវាស់វែងត្រូវតែធ្វើឡើងដោយប្រើឧបករណ៍សមស្របសម្រាប់វាស់ហើយក្រុមប្រកួតនិមួយៗត្រូវតែមានឧបករណ៍នេះ។ ហាមប្រើជើងជាឧបករណ៍សំរាប់វាស់។
អ្នកប្រកួតណាមួយមិនគោរពនូវបទបញ្ញាខាងលើនឹងត្រូវពិន័យតាមមាត្រា៣៥។

## មាត្រាទី២៧ ការដកប៊ូលចេញ

ហាមដកប៊ូលដែលលេងហើយមុនពេលចប់សេវា។ពេលចប់សេវាប៊ូលដែលដកចេញមុនការទូទាត់ពិន្ទុទុកជាអសារបង់ដោយគ្មានការតវ៉ា។បើសិនជាអ្នកប្រកួតម្នាក់លើកប៊ូលគាត់ចេញពីទីលានប្រកួត ហើយក្នុងពេលនោះគ្នារបស់គាត់នៅសល់ប៊ូលលេងប៊ូលដែលនៅសល់នោះទុកជាអសារបង់។

## មាត្រាទី២៨ ការវាស់វែងបានប៉ះប៊ូលឬប៊ី

គ្រាប់ប៊ូលរបស់ក្រុមវាស់ត្រូវទុកជាចាញ់បើសិនពេលកំពុងវាស់ស្រាប់តែប៉ះហើយរុញចេញប៊ូលឬគ្រាប់ប៊ី។ ករណីនេះបើធ្វើដោយអាជ្ញាកណ្តាលការសម្រេចអោយចាញ់ ឬឈ្នះជាបន្ទុករបស់អាជ្ញាកណ្តាល។

## មាត្រាទី២៩ ប៊ូលដែលមានចម្ងាយស្មើគ្នាពីប៊ី

បើសិនជាប៊ូល២គ្រាប់នៅជិតប៊ីជាងគេហើយប៊ូលនោះជាប៊ូលរបស់ម្ខាងម្នាក់ដែលមានប្រវែងស្មើគ្នាពីប៊ី, គេត្រូវយកពាករណីមកប្រើ៖

១) បើសិនជាក្រុមទាំង២គ្មានសល់ប៊ូល, សេវាហ្នឹងទុកជាស្មើគ្នារួចកូនប៊ីត្រូវប្រគល់ឲ្យក្រុមដែលឈ្នះសេវាមុនឬក្រុមដែលឈ្នះឆ្នោត។

២) បើសិនមានតែក្រុមមួយទេដែលនៅសល់ប៊ូល ក្រុមនោះត្រូវបន្តការប្រកួតជាធម្មតា។

៣) បើសិនជាក្រុមទាំង២នៅសល់ប៊ូល ក្រុមដែលបោះប៊ូលក្រោយគេត្រូវតែបោះមុនតាមលំដាប់លំដោយនៃក្រុម ទាល់តែរកក្រុមអ្នកឈ្នះឃើញទើបការប្រកួតប្រព្រឹត្តទៅជាធម្មតា។ បើនៅតែស្មើគ្នាបន្ទាប់ពីបោះអស់ប៊ូលរៀងខ្លួនគេទុកសេវានោះជាសូន្យ។

## មាត្រាទី៣០ របស់ដែលជាប់លើប៊ូលឬប៊ី

របស់អ្វីដែលជាប់លើប៊ូលឬលើប៊ីត្រូវតែយកចេញមុននឹងវាស់វែង។

## មាត្រាទី៣១ ការតវ៉ា

ការតវ៉ាត្រូវធ្វើឡើងនៅចំពោះមុខអាជ្ញាកណ្តាលក្នុងពេលកំពុងប្រកួត។ ពេលណាការប្រកួតចប់ហើយគេមិនអាចតវ៉ាបានទៀតទេ។

# វិន័យ

## <u>មាត្រាទី៣២ ពិន័យចំពោះការមិនបង្ហាញខ្លួនរបស់ក្រុមឬអ្នកប្រកួត</u>

នៅពេលចាប់ឆ្នោតប្រកួតនិងការប្រកាសនៃលទ្ធផលនៃការចាប់ឆ្នោតអ្នកប្រកួតទាំងអស់ត្រូវបង្ហាញខ្លួននៅទីកន្លែងចាប់ឆ្នោត។

បន្ទាប់ពី១៥នាទី ក្រោយពីការប្រកាសប្រកួត, ក្រុមដែលមិនបាន បង្ហាញខ្លួននៅលើទីលានប្រកួតត្រូវដក១ពិន្ទុឲ្យទៅក្រុមប្រជែង។ បន្ទាប់មកត្រូវដក១ពិន្ទុក្នុង៥នាទី។ បើសិនជាការប្រកួតកំរិតពេលវេលា,ពិន័យចាប់ផ្តើមបន្ទាប់ពី៥នាទីនៃការប្រកាសប្រកួត។

ការពិន័យនេះធ្វើឡើងនៅគ្រប់ពេលប្រកួតបន្ទាប់ពីការចាប់ឆ្នោតរួចឬក្នុងការបន្តប្រកួតបន្ទាប់ពីមានការបញ្ឈប់ប្រកួតដោយមូលហេតុអ្វីមួយ ។

ត្រូវដកចេញពីការប្រកួតទាំងមូលបើសិនជាក្រុមណាមួយមិនបានបង្ហាញខ្លួននៅលើទីលានប្រកួតតាមម៉ោងឬពេលវេលាដែលបានកំរិតអោយពីដំបូងឬការបន្តរការប្រកួត។

ក្រុមប្រកួតដែលខ្វះគ្នាមានសិទ្ធិចាប់ផ្តើមប្រកួតដោយមិនបាច់ចាំមិត្តរបស់ខ្លួនមកដល់ទេ ក៏ប៉ុន្តែត្រូវប្រើតែប៊ូលដែលគេកំរិតចំនួនអោយប្រើក្នុងម្នាក់ៗ។

គ្មានអ្នកប្រកួតណាមួយអាចអវត្តមានក្នុងពេលកំពុងប្រកួតឬចាកចេញពីទីលានប្រកួតដោយមិនបានសុំការអនុញ្ញាតពីអាជ្ញាកណ្តាល។ ទោះជាបានយល់ព្រមពីអាជ្ញាកណ្តាលក៏ដោយក៏ការប្រកួតនេះនិងប្រព្រឹត្តទៅជាធម្មតាតាមក្បួនច្បាប់ដែលចែងមក។ បើសិនជាការត្រឡប់មកវិញហួសពេលកំណត់របស់ក្បួនច្បាប់ដែលចែងថា១នាទីម្នាក់, ប៊ូលរបស់គាត់ត្រូវទុកជាអសារបង់។

(អាជ្ញាកណ្តាលមិនអាចចាំការត្រឡប់មកវិញនៃអ្នកអវត្តមានបានទេ៕ ការប្រកួតត្រូវតែធ្វើជាធម្មតាតាមច្បាប់ម្នាក់១នាទី)។

បើសិនជាអាជ្ញាកណ្តាលមិនព្រមអនុញ្ញាតឲ្យ, ប្រការនេះត្រូវតែពិន័យតាមមាត្រា៣៥។

បើសិនជាមានគ្រោះថ្នាក់ឬមានបញ្ហាសុខភាពដែលបានទទួលស្គាល់ដោយគ្រូពេទ្យ, គេអាចយល់ព្រមឲ្យបញ្ឈប់ការប្រកួតយ៉ាងយូរចំនួន១៥នាទី។ បើសិនជាការ

អនុញ្ញាតនោះបានឃើញជាចុងក្រោយថាអ្នកប្រកួតរូបនេះបានក្លែងបន្លំ, ក្រុមប្រកួតរបស់អ្នកបន្លំនិងអ្នកបន្លំនេះត្រូវបណ្តេញចេញពីការប្រកួត។

## មាត្រាទី៣៣ ការមកដល់កន្លែងប្រកួតយឺតយ៉ាវ

បើសិនជាការប្រកួតចាប់ផ្តើមហើយៗអ្នកប្រកួតដែលមិនបង្ហាញខ្លួនបានមកដល់ទីលាន, អ្នកនោះមិនអាចចូលប្រកួតបានភ្លាមទេត្រូវតែចាំដល់សេវាថ្មីទើបចូលបាន។
បើសិនជាអ្នកប្រកួតមិនបង្ហាញខ្លួនបានមកដល់ទីលានលើសពី១ម៉ោងគាត់ត្រូវបាត់បង់សិទ្ធិប្រកួត។
បើសិនជាមិត្តដៃគូប្រកួតរបស់គាត់ឈ្នះការប្រកួត, គាត់អាចចូលប្រកួតវិញបាននៅវគ្គថ្មីក៏ប៉ុន្តែគាត់ត្រូវតែមានឈ្មោះក្នុងក្រុមនិងក្នុងបញ្ជីប្រកួតដែលទទួលស្គាល់ដោយគណកម្មការប្រកួត។
បើសិនជាការប្រកួតប្រជែងមានលក្ខណៈជាពូល, គាត់អាចចូលប្រកួតក្នុងវគ្គទី២បានទោះបីជាលទ្ធផលនៃការប្រកួតទី១យ៉ាងណាក៏ដោយ។
កាលណាប៊ីបោះហើយសេវាប្រកួតត្រូវទុកជាការចាប់ផ្តើមហើយ។

## មាត្រាទី៣៤ ការផ្លាស់ប្តូរអ្នកប្រកួត

ការផ្លាស់ប្តូរអ្នកប្រកួតម្នាក់ក្នុងការប្រកួត២ទល់២ឬផ្លាស់ប្តូរ១ទៅ២នាក់ក្នុងការប្រកួត៣ទល់៣អាចធ្វើទៅបានមុនពេលប្រកាសជាផ្លូវការឈ្មោះអ្នកប្រកួត ។
អ្នកដែលផ្លាស់ប្តូរនោះមិនត្រូវមានការចុះឈ្មោះប្រកួតក្នុងក្រុមណាមួយទៀតទេ។

## មាត្រាទី៣៥ ការដាក់ទណ្ឌកម្ម

ការដាក់ទណ្ឌកម្មមាន៥ប្រការះ
១)ការព្រមានពីអាជ្ញាកណ្តាលដោយប្រើប័ណ្ណពណ៌លឿង។គេច្រើនប្រើករណីនេះចំពោះអ្នកកីឡាករណាដែលមិនគោរពពេលវេលានៃការបោះប៊ូល។បើបន្តធ្វើទៀតគេនិងដកប៊ូល១ចេញ។បើគ្មានប៊ូលនិងដកទេគេដកក្នុងសេវាក្រោយ។

២)ការទុកជាអសារបង់ប៊ូលដែលលេងហើយឬប៊ូលមិនទាន់លេងពីអាជ្ញាកណ្តាលដោយលើកប័ណ្ណពណ៌ទឹកក្រូច។

៣)ការបញ្ឈប់អ្នកប្រកួតដែលមានកំហុសធ្ងន់ក្នុងពេលប្រកួតដោយប្រើប័ណ្ណពណ៌ក្រហម។

៤)ការបណ្តេញចេញទាំងក្រុម។

៥)ការបណ្តេញចេញទាំង២ក្រុម ក្នុងការឃុបឃិតឬមិនសមស្របគ្នា។

គ្មានការព្រមានលើកទី២នៃប័ណ្ណពណ៌ទឹកក្រូចទេព្រោះទ័ណ្ឌកម្មបានធ្វើរួចហើយ។ ការព្រមានអាចទៅជាទណ្ឌកម្មបានទាល់តែឃើញច្បាស់ថាអំពើនោះជាបទល្មើសមែន។

ការជូនដំណឹងដល់អ្នកប្រកួតមុនពេលចាប់ផ្តើមប្រកួតមិនអាចទុកថាជាការព្រមានទេ។

## <u>មាត្រាទី៣៦ អាកាសធាតុអាក្រក់</u>

បើសិនជាភ្លៀងធ្លាក់, វគ្គប្រកួតត្រូវបញ្ឈប់,លើកលែងតែការសម្រេចផ្ទុយរបស់អាជ្ញាកណ្តាលតាមការពិគ្រោះជាមួយគណៈវិនិច្ឆ័យក្នុងការឲ្យឈប់ប្រកួតឬពីការបោះបង់ចោលការប្រកួតទាំងមូលក្នុងករណីប្រធានស័ក្តិ។

## <u>មាត្រាទី៣៧ ដំណាក់កាលថ្មីនៃការប្រកួត</u>

បើសិនជាការហៅឡើងប្រកួតនៃដំណាក់កាលថ្មី,ឧទាហរណ៍ដូចជាជុំទី២ឬទី៣នៃការប្រកួតស្រាប់តែពេលនោះមានការប្រកួតចាស់ខ្លះមិនទាន់ចប់, អាជ្ញាកណ្តាល, តាមសំណូមពររបស់គណៈកម្មការប្រកួត, អាចមានសិទ្ធិសម្រេចបាននូវការផ្លាស់ប្តូរដើម្បីឲ្យការប្រកួតទាំងមូលបានដើររលូន។

## <u>មាត្រាទី៣៨ កង្វះភាពជាកីឡា</u>

ក្រុមដែលកំពុងប្រកួតណាមួយដែលមានកង្វះភាពជាអ្នកកីឡាហើយគ្មានការគោរពអ្នកទស្សនា, អ្នកដឹកនាំ ឬ អាជ្ញាកណ្តាលនិងត្រូវបញ្ឈប់ចេញពីការប្រកួត។

ការបញ្ឈប់នេះអាចមិនទទួលស្គាល់លទ្ធផលដែលទទួលបានក្នុងការប្រកួត។ មិនតែប៉ុណ្ណោះថែមទាំងមានការអនុវត្តនូវទណ្ឌកម្មក្នុងមាត្រា៣៩។

## មាត្រាទី៣៩ ភាពមិនត្រឹមត្រូវ

អ្នកកីឡាដែលគេបានចាត់ទុកថាមានកំហុសកំរិតធ្ងន់ដូចជាធ្វើអំពើហិង្សាដល់អ្នកដឹកនាំ ដល់អាជ្ញាកណ្តាលដល់អ្នកប្រកួតឬដល់អ្នកចូលទស្សនានិងត្រូវធ្វើទណ្ឌកម្មដូចការចែងខាងក្រោមនេះ

១) ការបណ្តេញចេញពីការប្រកួត

២) ការដកហូតអាជ្ញាប័ណ្ណ

៣) ការរឹបអូសយកឬសងសំណងបដិទាននិងរង្វាន់

ទណ្ឌកម្មចំពោះអ្នកប្រកួតម្នាក់អាចប្រព្រឹត្តបានទៅលើក្រុមទាំងមូល។

ទណ្ឌកម្មទី១ខាងលើធ្វើតាមរយៈអាជ្ញាកណ្តាល

ទណ្ឌកម្មទី២ត្រូវធ្វើតាមរយៈគណៈវិនិច្ឆ័យ

ទណ្ឌកម្មទី៣ត្រូវធ្វើរតាមរយៈគណៈកម្មការរៀបចំការប្រកួត។ ក្នុងកំឡុងក្រោម៤៨ម៉ោងគណៈកម្មការនោះត្រូវផ្តល់របាយការណ៍និងការសម្រេចរបស់គេដល់សហព័ន្ធដើម្បីសម្រេចបន្ត។

ព្រឹត្តិការណ៍នេះបើសិនជាមានការពិបាកក្នុងការសម្រេចត្រូវតែដាក់បន្តរទៅទៀតឲ្យក្រុមព្រឹក្សាភិបាលរបស់សហព័ន្ធសម្រេចជាចុងក្រោយ។

អ្នកប្រកួតទាំងអស់ត្រូវតែមានសម្លៀកបំពាក់ត្រឹមត្រូវ, មិនឲ្យខ្លួនទទេ, ពាក់ស្បែកជើងការពារជើងបិតខាងលើ,ខាងមុខនិងខាងក្រោយ។

ហាមជក់បារីក្នុងពេលប្រកួតទោះបីជាបារីអេលិចត្រូនិចក៏ដោយ។

អាជ្ញាកណ្តាលអាចបញ្ឈប់មិនឲ្យប្រកួតបានបើសិនជាអ្នកប្រកួតណាមួយមិនព្រមធ្វើតាម, បន្ទាប់ពីមានការព្រមានពីគាត់។

## មាត្រាទី៤០ កាតព្វកិច្ចរបស់អាជ្ញាកណ្តាល

អាជ្ញាកណ្តាលដែលទទួលភារៈក្នុងការដឹកនាំការប្រកួតត្រូវតែតាមមើលឲ្យជិតដល់ឲ្យអ្នកប្រកួតគោរពនូវក្បួនច្បាប់ប្រកួតនិងក្បួនរដ្ឋបាលឲ្យបានត្រឹមត្រូវ។ គាត់មាន

សិទ្ធិនឹងបញ្ឈប់អ្នកប្រកួត ឬក្រុមប្រកួតដែលមិនព្រមធ្វើតាមបញ្ជារបស់គាត់។ អ្នកទស្សនាដែលមានអាជ្ញាប័ណ្ណឬអ្នកមានអាជ្ញាប័ណ្ណដែលត្រូវដកហូត, នឹងត្រូវអាជ្ញាកណ្តាលធ្វើរបាយការណ៍ផ្ញើទៅសហព័ន្ធបើសិនជាអ្នកនោះមានឥរិយាបទដែលបង្កនូវឧប្បត្តិហេតុក្នុង ទីលានប្រកួត។ អ្នកល្មើសនោះត្រូវសហព័ន្ធហៅឲ្យចូលខ្លួនទៅបង្ហាញនៅមុខគណៈកម្មាធិការវិន័យដើម្បីទទួលនូវទណ្ឌកម្មតាមកំរិតល្មើសរបស់ខ្លួន។

## <u>មាត្រាទី៤១ ការតែងតាំងនិងការសម្រេចរបស់គណៈវិនិច្ឆ័យ</u>

ករណីណាដែលគ្មានចែងក្នុងក្បួន, អាជ្ញាកណ្តាលអាចបញ្ជូនទៅគណៈវិនិច្ឆ័យនៃការប្រកួតដែលមានសមាជិកយ៉ាងតិច៣នាក់ហើយយ៉ាងច្រើន៥នាក់ដើម្បីសម្រេច។ ការសម្រេចតាមកថាខណ្ឌរបស់គណៈវិនិច្ឆ័យមិនអាចកែប្រែបានទេ។ ក្នុងការសម្រេចនេះបើមានសម្លេងស្មើរគ្នា, សម្លេងរបស់ប្រធានគណៈវិនិច្ឆ័យទុកជាឈ្នះ ។

**ក្បួនច្បាប់ដែលយកមកប្រើការនេះបានទទួលស្គាល់ថ្ងៃទី៧ខែតុលាឆ្នាំ២០១០ពីមហាសន្និបាទរបស់សហព័ន្ធអន្តរជាតិ(FIPJP)នៅអ៊ីមារនៃប្រទេសទួរគី។**

**ហើយបានកែតម្រូវនិងបន្ថែមនៅឆ្នាំ២០១៥**
**យកមកប្រើជាផ្លូវការឆ្នាំ២០១៧**

# ក្បួនច្បាប់នៃកីឡាប៉េតង់ខាងវិញ្ញាសារវាយស៊ីប




**ផ្សរូបភាព:**

នៃការវាយយកពិន្ទុដែលមានរង្វង់មូលមួយមានអង្កត់ផ្ចិត១ម៉ែត្រដែលគេសំរាប់ដាក់គ្រាប់ប៊ូល, ប៊ីស៊ីបនិងប៊ូលឧបសគ្គ។ រង្វង់មូល៤ទៀតដែលមានអង្កត់ផ្ចិតប្រវែង៥០សង់ទីម៉ែត្រដែលសម្រាប់អ្នកវាយឈរខាងក្នុង។

គ្រាប់ប៊ូលនិងកូនប៊ីជាស៊ីបឬជាឧបសគ្គត្រូវតែទទួលស្គាល់ពីសហព័ន្ធអន្តរជាតិហើយត្រូវតែមានពណ៌ដែលមើលឃើញច្បាស់ហើយមានផ្ទៃលាត,មានអង្កត់ផ្ចិត៧៤មីលីម៉ែត្រនិងទម្ងន់៧០០ក្រាម។

គ្រាប់ប៊ីត្រូវធ្វើអំពីឈើមានពណ៌ដែលមើលឃើញច្បាស់ហើយមានអង្កត់ផ្ចិត៣០សង់ទីម៉ែត្រនិងមានទម្ងន់ពី១០ទៅ១៨ក្រាម។

ប៊ូលឧបសគ្គត្រូវមានលក្ខណ:ដូចប៊ូលស៊ីបប៉ុន្តែត្រូវតែមានពណ៌ក្រម៉ៅ។

ក្នុងការប្រកួតរើសជើងឯកពិភពលោកប៊ូលនិងប៊ីដែលជាស៊ីបឬជាឧបសគ្គត្រូវតែរៀបចំឲ្យមានកន្លែងច្បាស់លាស់ដើម្បីដាក់វត្ថុទាំងនោះឲ្យចំទីកន្លែង។

រូបភាពទី១ រូបភាពទី២ ទី៣ ទី៤ ទី៥



រូបភាពទី១ (ប៊ូលស៊ីបដាក់ចំកណ្តាលរង្វង់មូលធំ)
រូបភាពទី២ (ប៊ូលស៊ីប១គ្រាប់នៅចំពាក់កណ្តាលរង្វង់មូលធំហើយប៊ីឧបសគ្គដាក់ពីមុខប៊ូលស៊ីបប្រវែង១០សង់ទីម៉ែត្រ)
រូបភាពទី៣ (ប៊ូលស៊ីប១គ្រាប់ចំពាក់កណ្តាលរង្វង់មូលធំហើយប៊ីឧបសគ្គ២គ្រាប់ដាក់ខាងឆ្វេង១គ្រាប់និងខាងស្តាំ១គ្រាប់ចម្ងាយ៣សង់ទីម៉ែត្រពីប៊ូលស៊ីប)
រូបភាពទី៤ (ប៊ូលស៊ីប១គ្រាប់ចំពាក់កណ្តាលរង្វង់ធំហើយប៊ូលឧបសគ្គ១គ្រាប់ស្ថិតនៅពីមុខដែលមានចម្ងាយ១០សង់ទីម៉ែត្រពីប៊ូលស៊ីប)
រូបភាពទី៥ (ប៊ីស៊ីបស្ថិតនៅ៣០សង់ទីម៉ែត្រពីកណ្តាលរង្វង់មូលចុះក្រោមនៃមុំ៩០អង្សារឬចម្ងាយ២០សង់ទីម៉ែត្រពីរង្វង់មូលភាគខាងក្រោម)
របៀបប្រជែង:
ក្នុងមួយរូបភាព,អ្នកកីឡាករត្រូវវាយប៊ូលស៊ីប៤ដងពី៤ចម្ងាយ:៦.៥, ៧.៥ ,៨.៥ ,៩.៥ ម៉ែត្រ។

**ការរាប់ពិន្ទុ**

វាយប៊ូលស៊ីប

បើត្រូវប៊ូលស៊ីបដោយមិនប៉ះប៊ូលឧបសគ្គហើយប៊ូលដែលបោះនោះស្ថិតក្នុងរង្វង់មូលបានពិន្ទុ៥។

បើត្រូវប៊ូលស៊ីបដោយមិនប៉ះប៊ូលឧបសគ្គហើយប៊ូលបោះនិងប៊ូលស៊ីបចាកចេញពីរង្វង់មូលបាន៣ពិន្ទុ។

បើវាយត្រូវប៊ូលស៊ីបហើយប៊ូលស៊ីបនោះមិនចេញពីរង្វង់មូលបាន១ពិន្ទុ។

បើវាយត្រូវប៊ូលស៊ីបហើយប៊ូលវាយប៉ះប៊ូលឧបសគ្គបាន១ពិន្ទុ។

វាយប៊ីស៊ីប:

ប៊ីដែលវាយត្រូវ,ហើយចាកចេញពីរង្វង់មូលបាន៥ពិន្ទុ

ប៊ីដែលវាយត្រូវហើយមិនចាកចេញពីរង្វង់មូលបាន៣ពិន្ទុ

ប៊ីដែលវាយត្រូវហើយមិនចាកចេញពីកន្លែងបាន០ពិន្ទុ

<u>ការកត់សំគាល់:</u>

. ប៊ូលបោះមិនត្រូវធ្លាក់ក្រៅរង្វង់មូលទេ

. ក្រៅរង្វង់បានន័យថាប៊ូលទាំងមូលធ្លាក់ក្រៅរង្វង់

. ក្នុងមួយរូបភាពត្រូវវាយ៨គ្រាប់ពីចម្ងាយ ៦.៥០, ៧.៥០, ៨.៥០, ៩.៥០ម៉ែត្របើវាយប៊ូលស៊ីប

. ក្នុងរូបភាពទី៥ជាការវាយប៊ីស៊ីបចម្ងាយ ៦.២០, ៧.២០, ៨.២០, ៩.២០ម៉ែត្រ។



# ទីលានលេងប៊ូលនៅស្តាតអូឡាំពិកភ្នំពេញ



**Féderation of cambodia pétanque and Petanque field in Olympic stadium in Phnom Penh**

